**“But for” Test (បើគ្មានអំពើ ក ក៏គ្មានលទ្ធផល ខ ដែរ)**

ក្នុងសំណុំរឿងព្រហ្មទណ្ឌ ដើម្បីឲ្យមានការទទួលខុសត្រូវ ទាមទារមានចំណងហេតុនិងផល (causation) ។ ទង្វើរបស់ជនល្មើស បង្កជាលទ្ធផលអ្វីមួយ។ មានមូលហេតជាក់ស្តែង (cause in fact) និង និងមូលហេតុផ្លូវច្បាប់ (legal cause) ដែលអាចដែលជាមូលហេតុកៀកគិត (proximate cause)។ ដើម្បីកំណត់ដឹង គេប្រើស្តង់ដារមួយគេហៅថា បើគ្មានអំពើហ្នឹង ក៏គ្មានលទ្ធផលហ្នឹងដែរ (but for test)។ នេះក្នុងន័យថា ការបង្កការខូចខាតនឹងមិនកើតឡើងទេ ប្រសិនបើគ្មានទង្វើប្រកបដោយឆន្ទៈរបស់របស់ជនល្មើស។

ទោះបីជាយ៉ាងនេះក្តី នៅក្នុងរឿងព្រហ្មទណ្ឌ ដើម្បីដាក់ឲ្យមានការទទួលខុសត្រូវ គេទាមទារថា អំពើរបស់ជនល្មើស មានចេតនា *(mens rea)* ដើម្បីនាំឱ្យមានការទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ដែរក៏ទាមទារឲ្យមាននូវការបំពេញកម្រិតភស្តុតាង (standard of proof) ហួសពីវិមតិសង្ស័យ (beyond reasonable doubt) ដែលភាគីចោទប្រកាន់ (រដ្ឋអាជ្ញា) ជាអ្នកមានបន្ទុកដាក់ភស្តុតាង (burden of proof) ក្នុងកម្រិតនេះ។

(Joshua Dressler, Understanding Criminal law, 5th ed., 2009, p. 184).